**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧២..អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់**
**និង ហិរញ្ញប្បទានភេរវកម្ម**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- អនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លេខ៦៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២
- យោងតាមសំណើរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានៃធនាគារជាតិនៃកម្ពុជា

**សម្រេច**

**មាត្រា ១.-** បង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហៅកាត់ថា "គ.ស.ហ" ជាយន្តការសម្របសម្រួលជាន់ខ្ពស់ និងអចិន្ត្រៃយ៍សម្រាប់ទប់ស្កាត់និងត្រួតពិនិត្យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រទេសកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

- ឧបនាយករដ្ឋមន្ត្រីប្រចាំការ ប្រធាន
- អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុប្រធានប្រចាំការ

- តំណាងគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម អនុប្រធាន
- សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងក្រសួងមហាផ្ទៃ សមាជិក
- សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងក្រសួងយុត្តិធម៌ សមាជិក
- សមាជិកក្រុមប្រឹក្សាភិបាល ស.ហ.ក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក និង
- អគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លេខាធិការ

គ.ស.ហ ត្រូវជួបប្រជុំ តាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ដោយមានការប្រគល់សិទ្ធិពីប្រធាន ។

**មាត្រា ២.-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ជាលេខាធិការដ្ឋានរបស់ គ.ស.ហ ។

**មាត្រា ៣.-** គ.ស.ហ មានសិទ្ធិអំណាចសម្រេចចិត្តតាមរយៈមតិភាគច្រើនរបស់សមាជិក ក្នុងការរៀបចំចាត់ចែងយន្តការសម្របសម្រួល ទប់ស្កាត់ និង ត្រួតពិនិត្យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រទេសកម្ពុជា។

**មាត្រា ៤.-** គ.ស.ហ មានមុខងារ និងភារកិច្ច ដូចខាងក្រោម ៖

១. បង្កើតគោលនយោបាយជាតិ និងយុទ្ធសាស្ត្រប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

២. សម្របសម្រួលគោលនយោបាយជាតិជាមួយការផ្តួចផ្តើមគំនិតក្នុងតំបន់ និងអន្តរជាតិ

៣. ធានាការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឲ្យមានប្រសិទ្ធភាព

៤. ធានាថាប្រទេសកម្ពុជាប្រតិបត្តិតាម៖
   - អនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force)
   - កាតព្វកិច្ចជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ និង
   - អនុសញ្ញា សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងផែនការសកម្មភាពប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់អង្គការសហប្រជាជាតិ

៥. បង្កើតប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៦. ផ្តល់អនុសាសន៍លើវិធានការរដ្ឋបាលនិងផ្លូវច្បាប់ និងលើរចនាសម្ព័ន្ធសម្រាប់ការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឲ្យបានត្រឹមត្រូវ

៧. លើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ និងសាធារណជនទូទៅ

៨. ធានាសម្របសម្រួលជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព អំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៩. តាមដានការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកបដោយប្រសិទ្ធភាព។

**មាត្រា ៥.-** អនុក្រឹត្យនេះជំនួស និងនិរាករណ៍អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២។

**មាត្រា ៦.-** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ប្រធានគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម អគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ